# មេរៀនទី ៣០ ៖ការអ៊ីនសម្លាប់អេបិល

## លោកុប្បត្តិ ៤៖១-១៦

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/hvZcWWzhRKA

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/vq46vNOkPs4

**គោលបំណង៖ ព្រះសាកសមនឹងទទួលរបស់ល្អបំផុតរបស់យើង។**

**ខគម្ពីរចងចាំ៖** រ៉ូម ១១៖៣៦ *"ដ្បិតរបស់សព្វសារពើបានកើតមកពីទ្រង់ ដោយសារទ្រង់ ហើយសំរាប់ទ្រង់ សូមឲ្យទ្រង់បានសិរីល្អនៅអស់កល្បជានិច្ច អាម៉ែន។"*

**ចំរៀង** ( *យូធូបលីង* )៖

១. តើអ្នកណាជាម្ចាស់នៃខ្ញុំ https://youtu.be/e4gCJBfWNTs

២. ហូសាណានៅស្ថានខ្ពស់បំផុត https://youtu.be/QWQ47zCVaCw

៣. ខ្ញុំថ្វាយបង្គំទ្រង់ https://youtu.be/1C4guXZFdAw

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «បញ្ជូនបាល់»**



សម្ភារៈដែលត្រូវការ៖ កែវជ័រធំ៦ ស្លាបព្រា១០ និងបាល់តូច៦

១. ចែកុមារជាពីរក្រុមដែលមួយក្រុមទទួលបាន កែវ ៣ ស្លាបព្រា ៥ និងបាល់តូច ៣ ហើយដាក់នៅលើតុសម្រាប់ក្រុមនីមួយៗ

២. ឲ្យក្រុមនីមួយៗ រើសតំណាង៣នាក់ មកកាន់តុ។ កុមារទី១ ត្រូវយកបាល់មួយមកដាក់ក្នុងស្លាបព្រា ទី១។ ហើយគេត្រូវជញ្ជូនបាល់នោះដោយមិនឲ្យជ្រុះនោះទេ។ ដោយបញ្ជូនបាល់នោះបន្តបន្ទាប់រហូត ដល់ស្លាបព្រាទី៥ ហើយប្រើស្លាបព្រាចុងក្រោយ យកបាល់ទៅដាក់ក្នុងកែវទី១។




៣. កុមារទី ២នឹងឡើងមកហើយលេងដូចកុមារទី១ដែរ។ ក្រុមណាដែលអាចយកបាល់ដាក់ចូលទៅក្នុងកែវបានគ្រប់៣មុន ក្រុមនោះជាអ្នកឈ្នះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ពួកគេបានព្យាយាមអស់ពីសមត្ថភាពក្នុងការលេងល្បែងនេះ ពីព្រោះព្រះ សាកសមទទួលបាននូវអ្វីដែលល្អបំផុតពីយើង។

**៤. ការណែនាំមេរៀន**

បើសិនអ្នកមានរបស់ចាស់មួយ និងរបស់ថ្មីមួយ តើមួយណាដែលអ្នកថ្វាយទៅព្រះ? ព្រះតែងតែប្រទានឲ្យយើងនូវអ្វីដែលល្អបំផុត ដូច្នេះជាធម្មជាតិរបស់យើង យើងត្រូវតែប្រទានអ្វីដែលល្អបំផុតដែលយើងមានថ្វាយទ្រង់។ ថ្ងៃនេះយើងនឹងរៀនពីបុរសម្នាក់ដែលបានជួបនឹងបញ្ហាពីព្រោះតែគាត់មិនបានគិតថាវាសំខាន់ដើម្បីថ្វាយរបស់ល្អបំផុតដែលគាត់មានទៅព្រះ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះមកពីព្រះគម្ពីរលោកុប្បត្តិ។ យើងបានដឹងថាបន្ទាប់ពីព្រះបានបង្កើតផែនដីហើយ ព្រះអង្គបានបង្កើតអ័ដាម និងអេវ៉ាដើម្បីរស់នៅលើផែនដីនេះ។ អ័ដាម និងអេវ៉ា មិនស្ដាប់បង្គាប់ព្រះ ហើយត្រូវចាកចេញពីសួនច្បារអេដែន។ ក្រោយមកអេវ៉ាមានកូនប្រុសម្នាក់ ហើយនាងបានដាក់ឈ្មោះថា កាអ៊ីន។ ក្រោយមកនាងក៏មានកូនម្នាក់ទៀត ជាប្អូនប្រុសរបស់កាអ៊ីន។ គាត់ឈ្មោះថា អេបិល! នៅពេលដែលក្មេងប្រុសទាំង២នេះបានធំធាត់ឡើង កាអ៊ីនបានដាំបន្លែដូចជាកសិករ ហើយអេបិលចិញ្ចឹមចៀមដូចជាអ្នកគង្វាលចៀម។

កាអ៊ីនបានប្រឹងធ្វើការនៅក្នុងចំការរបស់គាត់។ គាត់បានស្រោចទឹកដាក់ដំណាំ ហើយគាត់បានធ្វើស្មៅ។ អេបិលបានប្រឹងប្រែងធ្វើការថែទាំចៀមរបស់គាត់។ គាត់ត្រូវប្រាកដថាមានស្មៅខៀវខ្ចីដើម្បីឲ្យចៀមស៊ី និងមានទឹកត្រជាក់ឲ្យចៀមផឹក។ ថ្ងៃមួយកាអ៊ីន និងអេបិលបានយកដង្វាយរបស់ខ្លួនទៅថ្វាយព្រះ។ អេបិលបានថ្វាយរបស់ល្អបំផុតដែលគាត់អាចរកបាននៅក្នុងហ្វូងចៀមរបស់គាត់ថ្វាយទៅព្រះ ហើយព្រះសព្វព្រះទ័យខ្លាំងណាស់។ ប៉ុន្តែកាអ៊ីនមិនបានថ្វាយរបស់ដែលល្អបំផុតពីចំការរបស់គាត់ទៅព្រះទេ។ ព្រះមិនសព្វព្រះទ័យជាមួយកាអ៊ីនទេ ពីព្រោះអ្វីដែលព្រះចង់បានមិនមែនបន្លែដែលល្អបំផុតដែលកាអ៊ីនមានទេ ប៉ុន្តែអ្វីដែលព្រះចង់បាននោះគឺបេះដូងដ៏ល្អបំផុតរបស់កាអ៊ីនថ្វាយដល់ព្រះ។ កាអ៊ីនបានច្រណែនដែលអេបិលធ្វើអ្វីដែលត្រូវ។ ជំនួសឲ្យការនិយាយសូមទោសចំពោះព្រះ កាអ៊ីនបែរជាខឹងទៅវិញ។

កាអ៊ីនអាចនឹងនិយាយថា គាត់សុំទោស ហើយព្រះអាចនឹងអត់ទោសឲ្យគាត់។ កាអ៊ីនអាចរៀបចំដង្វាយផ្សេងទៀតជាមួយនឹងក្ដីស្រឡាញ់ថ្វាយទៅព្រះ ជំនួសឲ្យការខឹងជាមួយនឹងប្អូនប្រុសរបស់គាត់។ ផ្ទុយទៅវិញកាអ៊ីនបានសំរេចចិត្តមកសងសឹកអេបិលដែលធ្វើឲ្យគាត់មើលទៅអាក្រក់។ ដូច្នេះកាអ៊ីនបានសម្លាប់ប្អូនប្រុសរបស់គាត់។ បន្ទាប់មកកាអ៊ីនបានជួបទុក្ខលំបាកកាន់តែច្រើន។ មិនត្រឹមតែមិនបានថ្វាយដង្វាយ ដែលល្អបំផុតដែលគាត់មានថ្វាយទៅព្រះទេ តែគាត់ថែមទាំងធ្វើឲ្យអ្នកដទៃដែលថ្វាយដង្វាយដែលល្អ ហើយស្មោះស្ម័គ្របំផុតឈឺចាប់ទៅវិញ។

ព្រះសាកសមនឹងទទួលនូវដង្វាយដ៏ល្អបំផុតពីព្រោះព្រះអង្គស្រឡាញ់យើងខ្លាំងណាស់! ដង្វាយដែលល្អបំផុតដែលយើងអាចថ្វាយទៅព្រះគឺដួងចិត្តរបស់យើង។ គឺមានន័យថាយើងស្រលាញ់ព្រះជាខ្លាំង ហើយយើងនឹងថ្វាយអ្វីដែលល្អជាងគេដល់ទ្រង់។

## ៦. សំនួរពិភាក្សា

១. តើកូនប្រុសពីរនាក់របស់អ័ដាម និងអេវ៉ាមានឈ្មោះអ្វី? *(កាអ៊ីន និងអេបិល)*

២. តើការងាររបស់ពួកគេជាអ្វី? *(កាអ៊ីនជាកសិករ ហើយអេបិលជាអ្នកគង្វាល)*

៣. ហេតុអ្វីព្រះមិនសប្បាយចិត្តនឹងដង្វាយរបស់កាអ៊ីន? *(ដោយសារកាអ៊ីនមិនបានផ្ដល់អ្វីល្អបំផុតដែលគាត់មានដែលបង្ហាញពីចិត្តរបស់គាត់មិនពេញដោយសេចក្ដីស្រឡាញ់ចំពោះព្រះ)*

៤. តើអ្នកអាចថ្វាយអ្វីដែលល្អបំផុតដែលអ្នកមានដោយរបៀបណា? *(សូមឲ្យកុមារឆ្លើយ សរសើរដំកើងព្រះដោយសំឡេងខ្លាំងៗ អធិស្ឋានទៅព្រះដោយដឹងថាព្រះនឹងឆ្លើយតប ថែរក្សាមនុស្សដែលខ្វះខាត ។ល។)*

## ៧. ល្បែងកំសាន្ត «បោះបាល់ចូលកែវ»



សម្ភារៈដែលត្រូវការ៖ កែវប្លាស្ទិក៣ កូនបាល់ តុ ស្កុត

១. ចែកកុមារជា៣ ក្រុមហើយឲ្យពួកគេឈរជាជួរ

២. បិតកែវទាំង ៣ ភ្ជាប់ជាគែមតុ ហើយត្រូវកំណាត់ថា កែវណាសម្រាប់ក្រុមមួយណា

៣. ក្រុមនីមួយៗ ត្រូវព្យាយាមមៀលបាល់នោះចូលទៅក្នុងកែវរបស់ពួកគេ ដើម្បីទទួលបានពិន្ទុ។ ប្រសិន




បើបាល់ចូលទៅក្នុងកែវរបស់ក្រុមផ្សេងនោះគេមិនទទួលបានពិន្ទុនោះទេ។ ក្រុមណាដែលទទួលបានពិន្ទុ ច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា មានកិច្ចការជាច្រើនដែលយើងអាចធ្វើបានដើម្បីព្រះ។ ប៉ុន្តែយើងត្រូវតែធ្វើដូចជាអេបិល ហើយថ្វាយព្រះនូវអ្វីដែលល្អបំផុតដែលយើងមាន ដោយអស់អំពីចិត្ត។

## ៨. ខគម្ពីរចងចាំ

**រ៉ូម ១១៖៣៦** *"ដ្បិតរបស់សព្វសារពើបានកើតមកពីទ្រង់ ដោយសារទ្រង់ ហើយសំរាប់ទ្រង់ សូមឲ្យទ្រង់បានសិរីល្អនៅអស់កល្បជានិច្ច អាម៉ែន។"*

## ៩. ហាត្ថកម្ម «ព្រះជាម្ចាស់សមនឹងទទួលបានអ្វីដែលល្អបំផុតពីយើង»



សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្ម, កូល័រ, កន្ត្រៃ, កាវបិត

១. ចែកក្រដាសហត្ថកម្មដែលបានបោះពុម្ពរួចដល់កុមារម្នាក់១សន្លឹក ហើយឱ្យពួកគេផាត់ពណ៌វា។

២. ឱ្យពួកគេកាត់ រូបកាអ៊ីន និង រូបអេបិល។ សូមឲ្យកុមារបិទរូបអេបិលនៅខាងក្រោយ អាសនាដែលមាន បេះដូង ដើម្បីជានិមិត្តរូបថា ព្រះសព្វព្រះហឫទ័យនឹងដង្វាយរបស់អេបិល។ សូមឲ្យកុមារបិតរូបកាអ៊ីននៅ ខាងក្រោយអាសនាដែលគ្មានបេះដូង ដើម្បីជានិមិត្តរូបថាព្រះមិនពេញចិត្តនឹងដង្វាយរបស់កាអ៊ីន។

៣. ពន្យល់ដល់កុមារថា ព្រះសមនឹងទទួលបានរបស់ល្អបំផុតរបស់យើង ហើយតែងតែចង់ឱ្យបេះដូងរបស់យើងពោរពេញដោយសេចក្តីស្រឡាញ់ចំពោះទ្រង់។

## ១០. ចំរៀង (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះបានបង្រៀនយើងអំពីសេចក្តីស្រឡាញ់តាមរយៈជីវិតរបស់ព្រះយេស៊ូវ និងតាមរយៈគ្រួសាររបស់យើង។ តើព្រះបានបង្រៀនយើងអំពីសេចក្តីស្រឡាញ់តាមរយៈគ្រួសារដោយរបៀបណា? សូមចំណាយពេលខ្លះដើម្បីសរសេរកំណត់ត្រាផ្ញើរទៅសមាជិកគ្រួសារផ្ទាល់របស់អ្នកម្នាក់ៗ សូមបង្ហាញពួកគាត់ថាព្រះស្រឡាញ់អ្នកខ្លាំងប៉ុណ្ណា ហើយបង្ហាញក្តីស្រឡាញ់របស់អ្នកទៅកាន់ពួកគាត់គ្រប់គ្នាៗ។ ហើយអធិស្ឋានសំរាប់គ្រួសារសិស្សរបស់អ្នក ហើយទូលសូមព្រះឲ្យជួយសិស្សរបស់អ្នករៀនពីព្រះបន្ថែមទៀតតាមរយៈក្រុមគ្រួសាររបស់ពួកគេ។

# ព្រះសាកសមនឹងទទួលរបស់ល្អរបស់យើង









សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្ម, កូល័រ, កន្ត្រៃ, កាវបិត

១. ចែកក្រដាសហត្ថកម្មដែលបានបោះពុម្ពដល់កុមារម្នាក់១សន្លឹក ហើយឱ្យពួកគេផាត់ពណ៌វា។

២. ឱ្យពួកគេកាត់ រូបកាអ៊ីន និងរូបអេបិល។ សូមឲ្យកុមារបិទរូបអេបិល នៅខាងក្រោយអាសនាដែលមាន បេះដូង ដើម្បីជានិមិត្តរូបថា ព្រះសព្វព្រះ ហឫទ័យនឹងដង្វាយរបស់អេបិល។ សូមឲ្យកុមារបិតរូបកាអ៊ីននៅខាង ក្រោយអាសនាដែលគ្មានបេះដូង ដើម្បីជានិមិត្តរូបថាព្រះមិនពេញ ចិត្តនឹងដង្វាយរបស់កាអ៊ីន។

៤. ពន្យល់ដល់កុមារថា ព្រះសមនឹងទទួលបានរបស់ល្អបំផុតរបស់យើង ហើយតែងតែចង់ឱ្យបេះដូង របស់យើងពោរពេញដោយសេចក្តីស្រឡាញ់ចំពោះព្រះ។